**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ១ ប.ទ. អ៣ ថ្ងៃ សុក្រ ១៤កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មករា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីបកប្រែ TranslateKH ជំនាន់ទី២

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍(**ក.ប.ទ.**) មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា កន្លងមក **ក.ប.ទ.** បានដាក់កម្មវិធីបកប្រែ TranslateKH ជំនាន់ទី១ ទាំងនៅលើគេហទំព័រ និងតេឡេក្រាម ជូនសាធារណជនបានប្រើប្រាស់ជាសាធារណៈរួចហើយ។

ដើម្បីផ្តល់ជាជម្រើសនិងមានភាពងាយស្រួលដល់អ្នកប្រើប្រាស់លើកម្មវិធីបកប្រែ TranslateKH ជំនាន់ទី២ សម្រាប់បកប្រែពីភាសាខ្មែរទៅភាសាអង់គ្លេស និងពីភាសាអង់គ្លេសមកភាសាខ្មែរវិញបានលឿនរហ័ស **ក.ប.ទ.** បានបង្កើតកម្មវិធីទូរសព្ទគឺ TranslateKH ជំនាន់ទី២ និងបានដាក់ដំណើរការនៅក្នុង PlayStore និង AppStore ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចទាញយកបានដោយឥតគិតថ្លៃ។ បន្ថែមលើនេះ **ក.ប.ទ.** ក៏បានបង្កើតគេហទំព័រថ្មីមួយទៀតដែលមានអាសយដ្ឋាន **www.translate.kh** ដើម្បីឱ្យសាធារណជនងាយស្រួលចូលប្រើប្រាស់តាមកុំព្យូទ័រ និងងាយចងចាំឈ្មោះអាសយដ្ឋានគេហទំព័រផងដែរ។

កម្មវិធីបកប្រែ TranslatKH ជំនាន់ទី២ មានសមត្ថភាពខ្ពស់អាចយល់និងធ្វើការបកប្រែផ្អែកតាមបរិបទនៃខ្លឹមសារបកប្រែជាជាងបកប្រែផ្អែកតាមសំណង់ឃ្លាប្រយោគ ដោយប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត រួមបញ្ចូលជាមួយនិងបច្ចេកទេសសិក្សាស៊ីជម្រៅ (Deep Learning) និងម៉ូដែលភាសាធំ (Large Language Model)។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមប្រកាសដាក់ឱ្យប្រើប្រាស់កម្មវិធីទូរសព្ទ TranslateKH និងគេហទំព័រ **www.translate.kh** ជាសាធារណៈដោយឥតគិតថ្លៃចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សូម សាធារណជនទាំងអស់ ជ្រាបជាព័ត៌មាននិងចូលរួមប្រើប្រាស់កម្មវិធីបកប្រែ TranslateKH ឱ្យបានទូលំទូលាយ។

**សូមស្កេន QR Code ដើម្បី៖**

| | | |
|---|---|---|
| ទាញយកកម្មវិធីពី AppStore & PlayStore | ចូលប្រើកម្មវិធីបកប្រែ លើគេហទំព័រ www.translate.kh | ចូលប្រើកម្មវិធីបកប្រែ នៅលើតេឡេក្រាម |

អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ 120210
123 023 724 810
www.mptc.gov.kh